# ព្រះពុទ្ធ ២៨ ព្រះអង្គ

# វេមត្តកថា

## អាយុវេមត្ត , បមាណវេមត្ត , កុលវេមត្ត

## បធានវេមត្ត , រស្មីវេមត្ត , យានវេមត្ត

## ពោធិរុក្ខវេមត្ត , បល្លង្កវេមត្ត

" សម្តែងដោយអគ្គបណ្ឌិត ប៊ុត សាវង្ស "

នាសាលាសតិប្បដ្ឋានឃាត់ជំបង

ពិនិត្យ និងវាយកុំព្យូទ័រដោយ

ខ្ញុំព្រះករុណា អាត្មាភាព

**យង់ សុផារ៉ត** និងឧបាសក **ជឹម ជំនិត**

**ថ្ងៃ ៨ រោច . ស្រាពណ៍ . កុរ ព.ស ២៥៥១**

រាជរដ្ឋាភិបាលកម្ពុជា

# ព្រះពុទ្ធ ២៨ ព្រះអង្គ (ទេមត្តកថា)

នមោ មេ សព្វពុទ្ធានំ ឧប្បន្នានំ មហេសិនំ

ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំចំពោះព្រះពុទ្ធជាម្ចាស់គ្រប់ព្រះអង្គ ដែលបានត្រាស់រួចមកហើយ ព្រះអង្គស្វែងរកនូវគុណដ៏ធំ ( ព្រះសម្ពុទ្ធទាំងនោះគឺ )

១ តណ្ហង្ករោ មហាវីរោ ព្រះតណ្ហង្ករ ព្រះអង្គមានព្យាយាមធំ ។

២ មេធង្ករោ មហាយសោ ព្រះមេធង្ករ ព្រះអង្គមានយសធំ ។

៣ សរណង្ករោ លោកហិតោ ព្រះសរណង្ករ ព្រះអង្គធ្វើឱ្យជាប្រយោជន៍ដល់សត្វលោក ។

៤ ទីបង្ករោ ជុតិន្ធរោ ព្រះទីបង្ករ ព្រះអង្គទ្រទ្រង់នូវបញ្ញា ដ៏រុងរឿង ទ្រង់មានព្រះជន្មាយុ ១០ ម៉ឺនឆ្នាំ ទ្រង់មានព្រះកម្ពស់ ៨០ ហត្ថ ទ្រង់មានព្រះត្រកូលជាក្សត្រ ទ្រង់សាងព្រះផ្នួស ១០ ខែ ទ្រង់មានព្រះរស្មីមិនប្រាកដទេ ទ្រង់មានព្រះយានដោយដំរី ទ្រង់ត្រាស់ដឹងនៅក្រោមដើមលៀប ទ្រង់គង់នៅលើរតនបល្ល័ង្ក ដែលមានកម្ពស់ ៥៣ ហត្ថ ។

៥ កោណ្ឌញ្ញោ ជនប្បមោក្ខោ ព្រះកោណ្ឌញ្ញៈ ព្រះអង្គជា ប្រធាននៃពពួកជន ទ្រង់មានព្រះជន្មាយុ ១០ ម៉ឺនឆ្នាំ ទ្រង់មានព្រះកម្ពស់ ៨៨ ហត្ថ ទ្រង់មានព្រះត្រកូលជាក្សត្រ ទ្រង់សាងព្រះផ្នួស ១០ ខែ ទ្រង់មានព្រះរស្មីមិនប្រាកដ

ទេ ទ្រង់មានព្រះយានដោយរថ ទ្រង់ត្រាស់ដឹង នៅក្រោមដើមសាលកល្យាណី ទ្រង់គង់នៅលើ រតនបល្ល័ង្កដែលមានកម្ពស់ ៥៧ ហត្ថ ។

៦ **មង្គលោ បុរិសាសភោ** ព្រះមង្គល ព្រះអង្គ ជាបុរសដ៏ប្រសើរ ទ្រង់មានព្រះជន្មាយុ ៩ ម៉ឺន ឆ្នាំ ទ្រង់មានព្រះកម្ពស់ ៨៨ ហត្ថ ទ្រង់មាន ព្រះត្រកូលជាក្សត្រ ទ្រង់សាងព្រះផ្នួស ៨ ខែ ទ្រង់មានព្រះរស្មីម៉ឺនលោកធាតុ ទ្រង់មានព្រះ យានដោយសេះ ទ្រង់ត្រាស់ដឹងនៅក្រោមដើម ខ្លឹង ទ្រង់គង់នៅលើរតន បល្ល័ង្កដែលមានកម្ពស់ ៥៧ ហត្ថ ។

៧ **សុមនោ សុមនោ ធីរោ** ព្រះសុមន ព្រះអង្គជាអ្នកប្រាជ្ញ មានព្រះហឫទ័យដ៏ល្អ ទ្រង់

មានព្រះជន្មាយុ ៩ ម៉ឺនឆ្នាំ ទ្រង់ មានព្រះកម្ពស់ ៩០ ហត្ថ ទ្រង់មានព្រះត្រកូលជាក្សត្រ ទ្រង់សាងព្រះផ្នួស ១០ ខែ ទ្រង់មានព្រះរស្មីមិនប្រាកដទេ ទ្រង់មានព្រះយានដោយដំរី ទ្រង់ត្រាស់ដឹងនៅក្រោមដើមខ្នឹង ទ្រង់គង់នៅលើរតនៈបល្ល័ង្កដែលមានកម្ពស់ ៦០ ហត្ថ ។

៨ រេវតោ តេជញ្ញុនោ ព្រះរេវត ព្រះអង្គញុំាងសេចក្តីត្រេកអរឱ្យចម្រើន ទ្រង់មានព្រះជន្មាយុ ៦ ម៉ឺនឆ្នាំ ទ្រង់មានព្រះកម្ពស់ ៨០ ហត្ថ ទ្រង់មានព្រះត្រកូលជាក្សត្រ ទ្រង់សាងព្រះផ្នួស ៧ ខែ ទ្រង់មានព្រះរស្មីមិនប្រាកដទេ ទ្រង់មានព្រះយានដោយរថ ទ្រង់ត្រាស់ដឹងនៅក្រោមដើមខ្នឹង ទ្រង់គង់នៅលើ រតនបល្ល័ង្កដែលមាន

កម្ពស់ ៥៣ ហត្ថ ។

៩ សោភិតោ គុណសម្បន្នោ ព្រះសោភិត ព្រះអង្គបរិបូណ៌ដោយព្រះគុណ ទ្រង់មានព្រះជន្មាយុ ៩ ម៉ឺនឆ្នាំ ទ្រង់មានព្រះកម្ពស់ ៥៨ ហត្ថ ទ្រង់មានព្រះត្រកូលជាក្សត្រ ទ្រង់សាង ព្រះ ផ្នួស ៧ ថ្ងៃ ទ្រង់មានព្រះរស្មីមិនប្រាកដទេ ទ្រង់មានព្រះយាន ដោយប្រាសាទ ទ្រង់ត្រាស់ដឹងនៅក្រោមដើមខ្ទឹង ទ្រង់គង់នៅលើរតនបល្ល័ង្ក ដែលមានកម្ពស់ ៣៨ ហត្ថ ។

១០ អនោមទស្សី ជនុត្តមោ ព្រះអនោម_ទស្សី ព្រះអង្គឧត្តមជាងពពួកជន ទ្រង់មានព្រះ ជន្មាយុ ១០ ម៉ឺនឆ្នាំ ទ្រង់មានព្រះ កម្ពស់ ៥៨ ហត្ថ ទ្រង់មានព្រះត្រកូលជាក្សត្រ ទ្រង់សាង

ព្រះផ្នួស ១០ ខែ ទ្រង់មានព្រះវស្សាមិនប្រាកដ ទេ ទ្រង់មានព្រះយាន ដោយអង្រឹង ទ្រង់ត្រាស់ដឹងនៅក្រោមដើមអង្គ្រង ទ្រង់គង់នៅលើរតនបល្ល័ង្កដែលមានកម្ពស់ ៣៨ ហត្ថ ។

១១ បទុមោ លោកបជ្ជោតោ ព្រះបទុម ព្រះអង្គញ៉ាំងលោកឱ្យភ្លឺស្វាង ទ្រង់មានព្រះជន្មាយុ ១០ ម៉ឺនឆ្នាំ ទ្រង់មានព្រះកម្ពស់ ៥៨ ហត្ថ ទ្រង់មានព្រះត្រកូលជាក្សត្រ ទ្រង់សាងព្រះផ្នួស ៨ ខែ ទ្រង់មានព្រះវស្សាមិនប្រាកដទេ ទ្រង់មានព្រះយានដោយរថ ទ្រង់ត្រាស់ដឹងនៅក្រោមដើមម្រុំ ទ្រង់គង់នៅលើរតនបល្ល័ង្កដែលមានកម្ពស់ ៣៨ ហត្ថ ។

១២ នារទោ វរសារថី ព្រះនារទ ព្រះអង្គ

ដូចជាសារថីដ៏ប្រសើរ ទ្រង់មានព្រះជន្មាយុ ៩ ម៉ឺនឆ្នាំ ទ្រង់មានព្រះកម្ពស់ ៨៨ ហត្ថ ទ្រង់មានព្រះត្រកូលជាក្សត្រ ទ្រង់សាងព្រះផ្នួស ៧ ថ្ងៃ ទ្រង់មានព្រះរស្មីមិនប្រាកដទេ ទ្រង់មានព្រះយានដោយព្រះបាទ ទ្រង់ត្រាស់ដឹងនៅក្រោមដើមម្រុំ ទ្រង់គង់នៅលើរតនបល្ល័ង្ក ដែលមានកម្ពស់ ៥៧ ហត្ថ ។

១៣ មនុមុត្តរោ សត្តសារោ ព្រះបទុមុត្តរ ព្រះអង្គជាខ្លឹមសារនៃពួកសត្វ ទ្រង់មានព្រះជន្មាយុ ១០ ម៉ឺនឆ្នាំ ទ្រង់មានព្រះកម្ពស់ ៥៨ ហត្ថ ទ្រង់មានព្រះត្រកូលជាក្សត្រ ទ្រង់សាងព្រះផ្នួស ៧ ថ្ងៃ ទ្រង់មានព្រះរស្មី ១២ យោជន៍ ទ្រង់មានព្រះយានដោយប្រាសាទ ទ្រង់ត្រាស់ដឹងនៅ

ក្រោមដើមស្រល់ ទ្រង់គង់នៅលើរតនបល្ល័ង្ក ដែលមានកម្ពស់ ៣៨ ហត្ថ ។

១៤ សុមេធោ អប្បដិបុគ្គលោ ព្រះសុមេធ ព្រះអង្គរកបុគ្គលប្រៀបដូចគ្មាន ទ្រង់មានព្រះជន្មាយុ ៩ ម៉ឺនឆ្នាំ ទ្រង់មានព្រះកម្ពស់ ៨៨ ហត្ថ ទ្រង់មានព្រះត្រកូលជាក្សត្រ ទ្រង់សាងព្រះផ្នួស ៨ ខែ ទ្រង់មានព្រះរស្មីមិនប្រាកដទេ ទ្រង់មានព្រះយានដោយដំរី ទ្រង់ត្រាស់ដឹងនៅក្រោមដើមស្តៅ ទ្រង់គង់នៅលើរតនបល្ល័ង្កដែលមានកម្ពស់ ៥៧ ហត្ថ ។

១៥ សុជាតោ សព្វលោកគ្គោ ព្រះសុជាត ព្រះអង្គប្រសើរ លើសជាងសត្វលោកទាំងពួង ទ្រង់មានព្រះជន្មាយុ ៩ ម៉ឺនឆ្នាំ ទ្រង់មានព្រះ

កម្ពស់ ៥០ ហត្ថ ទ្រង់មានព្រះត្រកូលជាក្សត្រ ទ្រង់សាងព្រះផ្នួស ៩ ខែ ទ្រង់មានព្រះរស្មី មិនប្រាកដទេ ទ្រង់មានព្រះយានដោយសេះ ទ្រង់ត្រាស់ដឹងនៅក្រោមដើមប្ញស្សី ទ្រង់គង់នៅលើរតនបល្ល័ង្កដែលមានកម្ពស់ ៣២ ហត្ថ ។

**១៦ បិយទស្សី នរាសភោ** ព្រះបិយទស្សី ព្រះអង្គប្រសើរ ជាងនរជន ទ្រង់មានព្រះជន្មាយុ ៩ ម៉ឺនឆ្នាំ ទ្រង់មានព្រះកម្ពស់ ៨០ ហត្ថ ទ្រង់មានព្រះត្រកូលជាក្សត្រ ទ្រង់សាងព្រះផ្នួស ៦ ខែ ទ្រង់មានព្រះរស្មីមិនប្រាកដទេ ទ្រង់មានព្រះយានដោយរថ ទ្រង់ត្រាស់ដឹងនៅក្រោមដើមថ្កាន់ ទ្រង់គង់នៅលើរតនបល្ល័ង្ក ដែលមានកម្ពស់ ៥៣ ហត្ថ ។

១៧ អត្ថទស្សី ការុណិកោ ព្រះអត្ថទស្សី ព្រះអង្គប្រកបដោយករុណា ទ្រង់មានព្រះជន្មាយុ ១០ ម៉ឺនឆ្នាំ ទ្រង់មានព្រះ កម្ពស់ ៨០ ហត្ថ ទ្រង់ មានព្រះត្រកូលជាក្សត្រ ទ្រង់សាងព្រះផ្នួស ៨ ខែ ទ្រង់មានព្រះរស្មីមិនប្រាកដទេ ទ្រង់មានព្រះ យានដោយសេះ ទ្រង់ត្រាស់ដឹងនៅក្រោមដើម ចំប៉ា ទ្រង់គង់នៅលើរតនបល្ល័ង្កដែលមានកម្ពស់ ៥៣ ហត្ថ ។

១៨ ធម្មទស្សី តមោនុទោ ព្រះធម្មទស្សី ព្រះអង្គបន្ទោបង់នូវងងឹត ទ្រង់មានព្រះជន្មាយុ ១០ ម៉ឺនឆ្នាំ ទ្រង់មានព្រះកម្ពស់ ៨០ ហត្ថ ទ្រង់ មានព្រះត្រកូលជាក្សត្រ ទ្រង់សាងព្រះផ្នួស ៧ ថ្ងៃ ទ្រង់មានព្រះរស្មីមិនប្រាកដទេ ទ្រង់មាន

ព្រះឃានដោយប្រាសាទ ទ្រង់ត្រាស់ដឹងនៅក្រោមដើមទន្លាប់ ទ្រង់គង់នៅលើរតនបល្ល័ង្គ ដែលមានកម្ពស់ ៥៣ ហត្ថ ។

១៩ សិទ្ធត្ថោ អសមោ លោកេ ព្រះសិទ្ធត្ថ ព្រះអង្គឥតមានអ្នកណាស្មើក្នុងលោក ទ្រង់មានព្រះជន្មាយុ ១០ ម៉ឺនឆ្នាំ ទ្រង់មានព្រះកម្ពស់ ៦០ ហត្ថ ទ្រង់មានព្រះត្រកូលជាក្សត្រ ទ្រង់សាងព្រះផ្នួស ១០ ខែ ទ្រង់មានព្រះរស្មីមិនប្រាកដទេ ទ្រង់មានព្រះឃានដោយអជ្រើង ទ្រង់ត្រាស់ដឹងនៅក្រោមដើមកណ្ណិការ ទ្រង់គង់នៅលើរតន-បល្ល័ង្គ ដែលមានកម្ពស់ ៤០ ហត្ថ ។

២០ តិស្សោ ច អតុលោ ទេវោ ព្រះតិស្ស ព្រះអង្គប្រសើរ ជាងអ្នកប្រាជ្ញខាងសំដីទាំងឡាយ

ទ្រង់មានព្រះជន្មាយុ ១០ ម៉ឺនឆ្នាំ ទ្រង់មានព្រះកម្ពស់ ៦០ ហត្ថ ទ្រង់មានព្រះត្រកូលជា ក្សត្រ ទ្រង់សាងព្រះផ្នួស កន្លះខែ ទ្រង់មានព្រះរស្មីមិនប្រាកដទេ ទ្រង់មានព្រះយានដោយសេះ ទ្រង់ត្រាស់ដឹងនៅក្រោមដើមផ្ទង់ ទ្រង់គង់នៅលើរតនបល្ល័ង្កដែលមានកម្ពស់ ៤០ ហត្ថ ។

២១ ផុស្សោ ច អរហា ពុទ្ធោ ព្រះពុទ្ធទ្រង់ព្រះនាមផុស្ស ព្រះអង្គប្រទាននូវធម៌ដ៏ប្រសើរ ទ្រង់មានព្រះជន្មាយុ ៩ ម៉ឺនឆ្នាំ ទ្រង់មានព្រះកម្ពស់ ៥៨ ហត្ថ ទ្រង់មានព្រះត្រកូលជាក្សត្រ ទ្រង់សាងព្រះផ្នួស ៧ ថ្ងៃ ទ្រង់មានព្រះរស្មីមិនប្រាកដទេ ទ្រង់មានព្រះយានដោយដំរី ទ្រង់ត្រាស់ដឹងនៅក្រោមដើមកន្ទួតព្រៃ ទ្រង់គង់នៅលើ

រតនបល្ល័ង្កដែលមានកម្ពស់ ៣៨ ហត្ថ ។

២២ ទិឞស្សី ច អនូបមោ ព្រះវិបស្សី ព្រះអង្គឥតមានអ្នកណាប្រៀបផ្ទឹមបានឡើយ ទ្រង់មានព្រះជន្មាយុ ៨ ម៉ឺនឆ្នាំ ទ្រង់ មានព្រះកម្ពស់ ៨០ ហត្ថ ទ្រង់មានព្រះត្រកូលជាក្សត្រ ទ្រង់សាងព្រះផ្នួស ៨ ខែ ទ្រង់មានព្រះរស្មី ៧ យោជន៍ ទ្រង់មានព្រះយានដោយរថ ទ្រង់ត្រាស់ដឹងនៅក្រោមដើមបាដលិព្រឹក្ស ទ្រង់គង់នៅលើរតនបល្ល័ង្កដែលមានកម្ពស់ ៥៣ ហត្ថ ។

២៣ សិខី សព្វហិតោ សត្ថា ព្រះសិខី ព្រះអង្គជាគ្រូប្រៀនប្រដៅ ធ្វើឱ្យជាប្រយោជន៍ដល់សត្វទាំងពួង ទ្រង់មានព្រះជន្មាយុ ៧ ម៉ឺនឆ្នាំ ទ្រង់មានព្រះកម្ពស់ ៧០ ហត្ថ ទ្រង់មានព្រះត្រកូលជា

ក្សត្រ ទ្រង់សាងព្រះផ្នួស ៨ ខែ ទ្រង់មានព្រះ រស្មី ៣ យោជន៍ ទ្រង់មានព្រះយានដោយដំរី ទ្រង់ត្រាស់ដឹងនៅក្រោមដើមស្វាយស ទ្រង់គង់នៅលើរតនបល្ល័ង្ក ដែលមានកម្ពស់ ៣២ ហត្ថ ។

២៤ **វេស្សភូ សុខទាយកោ** ព្រះវេស្សភូ ព្រះអង្គប្រទាននូវសេចក្ដីសុខ ទ្រង់មានព្រះជន្មាយុ ៦ ម៉ឺនឆ្នាំ ទ្រង់មានព្រះ កម្ពស់ ៦០ ហត្ថ ទ្រង់មានព្រះត្រកូលជាក្សត្រ ទ្រង់សាងព្រះផ្នួស ៦ ខែ ទ្រង់មានព្រះរស្មីមិនប្រាកដទេ ទ្រង់មានព្រះយានដោយអង្រឹង ទ្រង់ត្រាស់ដឹងនៅក្រោមដើមមហាសាលព្រឹក្ស ទ្រង់គង់នៅលើរតនបល្ល័ង្ក ដែលមានកម្ពស់ ៤០ ហត្ថ ។

២៥ **កកុសន្ធោ សត្ថវាហោ** ព្រះកកុសន្ធ

ព្រះអង្គនាំសត្វ ចេញចាកផ្លូវឆ្ងាយដាច់ស្រយាល គឺ កិលេស ទ្រង់មានព្រះជន្មាយុ ៤ ម៉ឺនឆ្នាំ ទ្រង់មានព្រះកម្ពស់ ៤០ ហត្ថ ទ្រង់មានព្រះត្រកូលជាព្រាហ្មណ៍ ទ្រង់សាងព្រះផ្នួស ៨ ខែ ទ្រង់មានព្រះរស្មី ១០ យោជន៍ ទ្រង់មានព្រះយានដោយរថ ទ្រង់ត្រាស់ដឹងនៅក្រោមដើមច្រេស ទ្រង់គង់នៅលើរតនបល្ល័ង្ក ដែលមានកម្ពស់ ២៦ ហត្ថ ។

២៦ កោនាគមនោ រណញ្ញោហោ ព្រះកោនា-គមន ព្រះអង្គបំបាត់បង់នូវសត្រូវ គឺ កិលេស ទ្រង់មានព្រះជន្មាយុ ៣ ម៉ឺនឆ្នាំ ទ្រង់មានព្រះកម្ពស់ ៣០ ហត្ថ ទ្រង់មានព្រះត្រកូលជាព្រាហ្មណ៍ ទ្រង់សាងព្រះផ្នួស ៦ ខែ ទ្រង់មានព្រះរស្មីមិន

ប្រាកដទេ ទ្រង់មានព្រះឃានដោយដំរី ទ្រង់ត្រាស់ដឹងនៅក្រោមដើមល្វា ទ្រង់គង់នៅលើរតន-បល្ល័ង្កដែលមានកម្ពស់ ២០ ហត្ថ ។

២៧ កស្សបោ សិរិសម្ភវោ ព្រះកស្សប ព្រះអង្គបរិបូណ៌ ដោយសិរីទ្រង់មានព្រះជន្មាយុ ២ ម៉ឺនឆ្នាំ ទ្រង់មានព្រះកម្ពស់ ២០ ហត្ថ ទ្រង់មានព្រះត្រកូលជាព្រាហ្មណ៍ ទ្រង់សាងព្រះផ្នួស ៧ ថ្ងៃ ទ្រង់មានព្រះរស្មីមិនប្រាកដទេ ទ្រង់មានព្រះឃានដោយប្រាសាទ ទ្រង់ត្រាស់ដឹងនៅក្រោមដើមជ្រៃ ទ្រង់គង់នៅលើរតនបល្ល័ង្កដែលមានកម្ពស់ ១៥ ហត្ថ ។

២៨ គោតមោ សក្យបុង្គវោ ព្រះគោតម ព្រះអង្គប្រសើរចម្បងជាងពួកសក្យរាជ ទ្រង់មាន

ព្រះជន្មាយុ ១០០ ឆ្នាំ ទ្រង់ មានព្រះកម្ពស់ ១៦ ហត្ថ ទ្រង់មានព្រះត្រកូលជាក្សត្រ ទ្រង់សាងព្រះផ្នួស ៦ ឆ្នាំ ទ្រង់មានព្រះរស្មីមួយព្យាម ទ្រង់មានព្រះយានដោយសេះ ទ្រង់ត្រាស់ដឹងនៅក្រោមដើមអស្សត្ថព្រឹក្ស ទ្រង់គង់នៅលើរតនបល្ល័ង្កដែលមានកម្ពស់ ១៤ ហត្ថ ។

**សូមអនុមោទនា បុណ្យ !!!**

បុណ្យនាំមកនូវសេចក្តីសុខចម្រើនកើនសម្បត្តិហូរហៀរ

**ចប់**

# បូជាធម្មទាន

## ដោយសប្បុរសជន ជាសិស្សគណ

## គោរពជូន

## លោគ្រូអគ្គបណ្ឌិត ប៊ុត  សាវង្ស